# ព្រះវិហារហ្លួងអាយុកាល១១៨ឆ្នាំ នៅវត្តជ្រោយតាកែវ

វត្តជ្រោយតាកែវ ឬវត្តព្រះស៊ីសុវត្ថិរតនារាម គឺជាអារាមហ្លួងដែលបានកសាងឡើងនៅប្របដងទន្លេបាសាក់ ស្ថិតនៅក្នុងឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល។ គេកត់ចំណាំថា វត្តនេះទទួលការទំនុកបម្រុងកសាងឡើងដោយ **ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ "ព្រះរាជានុកោដ្ឋ"** តាំងពីពុទ្ធសករាជ២៤៣៩ ត្រូវនឹងគ្រិស្តសករាជ១៨៩៥។ រីឯព្រះវិហារ កសាងឡើងក្នុងពុទ្ធសករាជ២៤៤៩ ពោលគឺត្រូវនឹងគ្រិស្តសករាជ១៩០៥ (រូបលេខ១)។[១] អ្នកសិក្សាភាគច្រើនយល់ថា គំនូរក្នុងព្រះវិហារបុរាណនេះមានលក្ខណៈប្រហាក់ប្រហែលនឹងគំនូរនៅវត្តកំពង់ត្រឡាចលើ(កំពង់ឆ្នាំង) ហើយជាគំនូរបុរាណចាស់ជាងគេនៅកម្ពុជា។[២] ប៉ុន្តែនៅក្នុងសម័យសង្គ្រាម ព្រះវិហារខាងលើក៏រងការបំផ្លិចបំផ្លាញយ៉ាងច្រើន រហូតដល់រវាងពាក់កណ្ដាលទសវត្សរ៍ទី៨០ និង៩០ ទើបពុទ្ធបរិស័ទជិតឆ្ងាយមូលមាត់គ្នាជួសជុលឡើងវិញ។



រូបលេខ១ ព្រះវិហារបុរាណវត្តជ្រោយតាកែវ (មើលពីជ្រុងអាគ្នេយ៍)

[១] កាលបរិច្ឆេទទាំងនេះគេបានកត់ចំណាំនៅផ្នែកខាងលិចព្រះវិហារ។

[២] *Daniel Guéret & Dominique-Pierre Guéret 2017: 71*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាការពិត វត្តជ្រោយតាកែវគឺជាអារាមហ្លួងស្ថាបនាឡើងតាំងពីចុងសតវត្សរ៍ទី១៩ លើផ្ទៃដីទទឹង១៦០ម៉ែត្រ បណ្តោយ៤០០ម៉ែត្រ ព្រមទាំងប្រកបដោយការរៀបចំប្លង់ទូទៅ និងក្បាច់រចនាលម្អលើផ្នែកផ្សេងៗនៃសំណង់យ៉ាងល្អវិចិត្រ។ ទន្ទឹមនឹងនេះ បើផ្អែកតាមរូបថតឯកសារថតឆ្នាំ១៩២៩ គេឃើញព្រះវិហារសង់នៅលើខឿនពីរថ្នាក់ ហើយនៅតាមជណ្តើរឡើងមានចម្លាក់តោមួយគូ និងយក្សឈរអមផង (រូបលេខ២២)។ រីឯនៅក្បែរព្រះវិហារត្រង់ជ្រុងពាយ័ព្យ មានពោងជួងមួយដែលសល់ដល់សព្វថ្ងៃ (រូបលេខ២៣) ហើយមានលក្ខណៈដូចគ្នានឹងពោងជួងក្នុងវត្តឧបោសថរតនារាមក្នុងព្រះបរមរាជវាំងដែរ។ ស្ថិតនៅខាងក្រោយឆ្ងាយពីព្រះវិហារ ពោលគឺនៅជាប់នឹងមាត់ច្រាំងទន្លេ គេឃើញមានសាលាសំណាក់មួយតូចច្រឡឹងសង់អំពីឈើ (រូបលេខ២៤)។



*រូបលេខ២២ ព្រះវិហារថតពីខាងកើត*
*(រូបថត៖ **EFEO**, ឆ្នាំ១៩២៩)*



*រូបលេខ២៣ ពោងជួង*
*(រូបថត៖ **EFEO**, ឆ្នាំ១៩២៩)*



*រូបលេខ២៤ សាលាសំណាក់*
*(រូបថត៖ **EFEO**, ឆ្នាំ១៩២៩)*

ដោយឡែក ចំពោះទម្រង់ស្ថាបត្យកម្មព្រះវិហារវត្តជ្រោយតាកែវ គឺជាទម្រង់ព្រះវិហារមួយបែបដែលអ្នកស្រាវជ្រាវហៅថា "ព្រះវិហារជហ្វា៤" ឬ "ព្រះវិហារបុរាណ"។[៣] បើផ្អែកតាមកាលបរិច្ឆេទខាងលើ ព្រះវិហារនេះកសាងឡើងក្រោយកកើតជាវត្តបាន១០ឆ្នាំ ហើយគិតមកដល់សព្វថ្ងៃ គឺមានអាយុកាល១១៨ឆ្នាំ។ ប៉ុន្តែយ៉ាងណាក្តីគេមើលឃើញថា រហូតមកដល់បច្ចុប្បន្ន ព្រះវិហារបុរាណវត្តជ្រោយតាកែវ នៅតែរក្សាទម្រង់ទូទៅបានល្អ

[៣] ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

គួរឱ្យកត់សម្គាល់។ នៅអមជណ្ដើរឡើងទាំងបួនទិសត្រង់ខឿនខាងក្រោម មានចម្លាក់តោនិងយក្សអមដូចគ្នាទាំងអស់(រូបលេខ២៥) ហើយថែមទាំងមានរបងព័ទ្ធជុំវិញផង។ ចំណែកឯនៅខឿនខាងលើ គេសាងឡើងឱ្យមានជណ្ដើរតែផ្នែកខាងកើតនិងខាងលិចតែប៉ុណ្ណោះ ដោយខាងកើតមានទ្វារពីរ ខាងលិចមានទ្វារពីរ (រូបលេខ២៦)។



រូបលេខ២៥ ព្រះវិហារមើលពីលិច



រូបលេខ២៦ បរិវេណព្រះវិហារនៅខឿនថ្នាក់ទី១

ព្រះវិហារវត្តជ្រោយតាកែវ សង់ឡើងអំពីឥដ្ឋបូកកំបោរបាយអ និងមានសសរខាងក្នុងជាឈើ ព្រមទាំងគ្រឿងបង្គុំខាងលើជាឈើដែរ។ ព្រះវិហារនេះមានទទឹង៣ល្វែង មានសសរបេតុងមូលធំៗជុំវិញបាំងសាច។ នៅតាមក្បាលសសរទាំងអស់នោះ គេឃើញមានរូបគ្រុឌទ្រវងស្បូវ ដែលទំនងជាទើបនឹងប្ដូរក្នុងពេលជួសជុលព្រះវិហារ ដ្បិតបើពិនិត្យលើរូបថតឯកសារឆ្នាំ១៩២៩ គឺមានរូបអែវ៉ាតាមក្បាលសសរកណ្ដាល ហើយគ្រុឌនៅតាមសសរចែង។ ប៉ុន្តែចំពោះក្បាច់រងស្បូវ គឺជាក្បាច់កញ្ចាំង ឆ្លាក់ពីឈើរំលេចពណ៌ទឹកមាស ដែលគេយល់ថាជាក្បាច់លម្អដើមរបស់ព្រះវិហារខាងលើ (រូបលេខ២៧-៨)។





រូបលេខ២៧-៨ ការលម្អលើក្បាលសសរជុំវិញព្រះវិហារ និងក្បាច់លម្អតាមរោងស្បូវ

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

ដំបូលព្រះវិហារ ជាដំបូលប្រក់ក្បឿងរលោង ជ្រាលចុះសងខាងបីថ្នាក់តាមលំនាំជាព្រះវិហារជហ្វា៤។ តាមចុងចែងដំបូលនីមួយៗលម្អដោយនាគចែងទាំងអស់។ ចំណែកឯក្បាច់លម្អតាមហោជាងទាំងពីរ គឺជាប្រភេទក្បាច់ភ្ញីទេសលាបពណ៌មាស ឆ្លាក់យ៉ាងរស់រវើកព័ទ្ធជុំវិញរូបព្រះរាជសង្ហារនៅចំកណ្ដាលនៅលើឈើបន្ទះក្ដារបញ្ឈរ។ នៅត្រង់គល់ហោជាង ជាក្បាច់កញ្ចាំងដូចក្បាច់លើរងស្បូវដែរ (រូបលេខ៩-១០)។ បើមើលហួសដល់របនាសម្ព័ន្ធនិងការលម្អផ្នែកខាងក្រៅនៃជញ្ជាំងវិញ គេឃើញនៅតាមស៊ុមទ្វារនិងបង្អួចនីមួយៗ សុទ្ធតែលម្អដោយក្បាច់ភ្ញីទេស ហើយនៅត្រង់ចំណុចកណ្ដាលនៃក្បាច់ស៊ុមទ្វារ គឺជារូបស្វេតឆត្រ និងមកុដតម្កល់លើជើងពាន ក្នុងរង្វង់កម្រងស្លឹកឈើ ហើយគេឃើញមានចារឹកព្យញ្ជនៈ "ស" នៅខាងក្រោមនោះផង។[៦]




រូបលេខ៩-១០ ក្បាច់លម្អលើហោជាងខាងកើត និងហោជាងខាងលិច

នៅផ្នែកខាងក្នុងព្រះវិហារ គេសង់ចែកជា៣ល្វែង គឺល្វែងគ្រឹះនៅកណ្ដាល អមដោយរបៀងសងខាង ហើយមានសសរឈើមូលធំៗពីរជួរ ទ្រពិតានឈើ និងគ្រឿងបង្គុំខាងលើ។ បើមើលតាមរូបថតឯកសារឆ្នាំ១៩២៩ ព្រះបដិមាព្រះជីវ៍ធំក្នុងព្រះវិហារនេះតម្កល់លើបល្ល័ង្កខ្ពស់មួយស្ថិតនៅចុងខាងលិចល្វែងគ្រឹះ (រូបលេខ១១)។ ប៉ុន្តែក្នុងសម័យសង្គ្រាមព្រះជីវ៍ធំនេះរងការបំផ្លិចបំផ្លាញ ហើយចូលដល់ឆ្នាំ១៩៨៥ ទើបពុទ្ធបរិស័ទដិតថ្វាយកសាងបល្ល័ង្កថ្មី និងតម្កល់ព្រះជីវ៍ថ្មីពណ៌ទឹកមាស សម្រាប់គោរពបូជាដូចឃើញមកដល់សព្វថ្ងៃ (រូបលេខ១២)។ មិនតែប៉ុណ្ណោះ បើគេសង្កេតមើលជើងសសរខាងក្នុងព្រះ

[៦] នៅលើក្បាច់ប្រថាប់លើផ្ទៃជញ្ជាំងខាងក្រៅ គេឃើញមានអក្សរ "អេស (S)" ដែលអក្សរទាំងនេះ (ស ឬ S) ប្រហែលតំណាងព្រះនាមព្រះមហាក្សត្រ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

វិហារសព្វថ្ងៃ គេឃើញមានការជួសជុលកែលម្អដោយប្រើបំពង់ទីបជ័រការពារការពុកផុយជើងសសរ។



រូបលេខ១១ ព្រះដីរ៍ដើមនៃវត្តជ្រោយតាកែវ (រូបថត៖ ***EFEO***, ឆ្នាំ១៩២៩)



រូបលេខ១២ ទិដ្ឋភាពខាងក្នុងព្រះវិហារ និងព្រះដីរ៍វត្តជ្រោយតាកែវសព្វថ្ងៃ

ចំណែកឯគំនូរខាងក្នុងព្រះវិហារ គេចាត់ទុកជាប្រភេទគំនូរបុរាណ ដែលគូរសាច់រឿងក្នុងទសជាតក និងពុទ្ធប្រវត្តិ។[៥] សាច់រឿងផ្ដើមចេញពីជញ្ជាំងផ្នែកខាងកើតជ្រុងខាងត្បូង បន្តមកជញ្ជាំងខាងត្បូងព័ទ្ធទៅខាងលិច និងខាងជើង រហូតទៅបញ្ចប់នៅលើជញ្ជាំងខាងកើតដែរ។ នៅតាមជើងជញ្ជាំងជុំវិញ គេគូរជារូបទេវតា យក្ស ឥសី... កាន់ផ្កាឈូកអង្គុយប្រណម្យនៅចន្លោះផ្ចិតចាមរ។ នៅចុងជញ្ជាំងខាងលើ ត្រង់ចំណុចហប់ខ្យល់ក៏ឃើញគូរតួអង្គដូចគ្នានឹងជើងជញ្ជាំងដែរ។ រីឯនៅតាមសន្ទឹកទ្វារនិងបង្អួចផ្នែកខាងក្នុងគេគូរលម្អជារូបតួអង្គផ្សេងៗក្នុងរឿងរាមកេរ្តិ៍(?)។

តាមការសិក្សារបស់ *Daniel Guéret* និង *Dominique-Pierre Guéret* បានឱ្យដឹងថាផ្ទាំងគំនូរក្នុងព្រះវិហារវត្តជ្រោយតាកែវ គឺជាគំនូរចាស់ជាងគេ ហើយជួសជុលក្នុងឆ្នាំ១៩៩០ ដោយប្រើថ្នាំប្រេង ដែលគេយល់ថាជួសជុលមិនសូវបានល្អ បាត់តួអង្គមួយចំនួន ខ្វះខាតចំណុចលម្អិតលើសម្លៀកបំពាក់ និងលក្ខណៈពិសេសលើគំនូរមួយចំនួនទៀត (រូបលេខ ១៣-១៤)។[៦] មិនតែប៉ុណ្ណោះនៅត្រង់ផ្ទាំងគំនូរជួសជុលក្រោយ គេសង្កេតឃើញវិចិត្រករ

---

[៥] ព្រាប ចាន់ម៉ារ៉ា ២០០៥-២០០៦: ៦៦-៦៧

[៦] *Daniel Guéret & Dominique-Pierre Guéret 2017: 71*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ប្រើពណ៌ស្រស់ឆើតខ្លាំងជាងគំនូរដើមៗ លក្ខណៈនេះ ហាក់ឆ្លងមកពីរបៀបគំនូរទំនើប ឬគំនូរសម័យ ដែលពេញនិយមចាប់ពីរវាងទសវត្សរ៍ទី៤០។ សូមបញ្ជាក់ថា គេពុំដឹងថា គំនូរដើមក្នុងព្រះវិហារនេះគូរដោយវិចិត្រករណាឡើយ តែការជួសជុលឡើងវិញ គឺជាស្នាដៃរបស់លោកតា ប៊ូ ម៉េង ដែលលោកធ្លាប់បង្រៀនគំនូរនៅសាលារចនា។[1]



រូបលេខ១៣ គំនូរលើជញ្ជាំង សន្ទឹកបង្អួច និងជើងជញ្ជាំងថតឆ្នាំ១៩២៩ (រូបថត៖ *EFEO*)



រូបលេខ១៤ គំនូរលើជញ្ជាំង សន្ទឹកបង្អួច និងជើងជញ្ជាំងក្រោយជួសជុលរួច





រូបលេខ១៥-១៦ គំនូរបង្ហាញអំពីអន្ទើផ្សេងៗក្នុងរឿងពុទ្ធប្រវត្តិ

[1] លោកតា ប៊ូ ម៉េង ជាអតីតអ្នកទោសនៅគុកទួលស្លែង ដែលមានស្រុកកំណើតនៅស្រុកកោះធំ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ១១៧ គំនូររឿងសុវណ្ណសាម*



*រូបលេខ១១៨ គំនូររឿងវេស្សន្តរ*

សង្ខេបសេចក្តីមក ព្រះវិហារវត្តជ្រោយតាកែវ គឺជាព្រះវិហារដែលស្ថាបនាឡើងដោយព្រះរាជទ្រព្យព្រះមហាក្សត្រ និងជាព្រះវិហារបុរាណមានអាយុកាលជាងសតវត្សរ៍មកហើយ។ ការរៀបចំនិងក្បូនខ្នាតសំណង់ គឺមានលក្ខណៈសមស្ធនជារបៀបព្រះវិហារជហ្វា៤ ដែលពុំធំខ្ពស់ហួសមាឌ។ ចំពោះគំនូរខាងក្នុងព្រះវិហារ គឺនៅរក្សាប្រធានបទគំនូរតាមផ្ទាំងនីមួយៗដូចដើម ដែលគេអាចសិក្សាបានតទៅថ្ងៃមុខ។

## ឯកសារយោង


ព្រាប ចាន់ម៉ារ៉ា

២០០៥-២០០៦, "គំនូរបុរាណ", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២១, ទំ.៦៦-៦៧, Friends of Khmer Culture

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

Daniel Guéret & Dominique-Pierre Guéret

2017, *The Khmer Pagoda*, KAM Editions


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត